# សាលា អភិវឌ្ឍន៍ អាស៊ី
# ASIA DEVELOPMENT SCHOOL

## បទបញ្ជាផ្ទៃក្នុងសំរាប់សិស្សានុសិស្ស
## STUDENT DISCIPLINARY RULE

### ចំពោះថ្នាក់រៀន និង មិត្តរួមថ្នាក់

ប្រការទី១ : សិស្សានុសិស្សទាំងអស់ត្រូវមករៀនអោយបានទៀងទាត់ និង ទាន់ពេលវេលា ។ ករណីមកយឺត១៥នាទីទុកថាអវត្តមាន ។ ត្រូវទៅសុំការអនុញ្ញាតិពីនាយកសាលា ឬ ប្រធានវិន័យជាចាំបាច់ ។

ប្រការទី២ : មិនត្រូវបង្ករសំលេងអ៊ូរអរដែលបង្ករអោយខូចសណ្តាប់ធ្នាប់ រឺ រំខានដល់ថ្នាក់ដ៏ទៃ ។

ប្រការទី៣ : ហាមខាកស្តោះ រឺ ចោលសំរាមក្នុងថ្នាក់រៀន ។ ហាមប្រើពាក្យអាសអាភាស ( ជេរ.ដៀល) ចំពោះមិត្តរួមថ្នាក់ ។

ប្រការទី៤ : សិស្សានុសិស្សាទាំងអស់ត្រូវដាក់កង់ម៉ូតូអោយបានត្រឹមត្រូវតាមការកំណត់របស់សាលា ។

ប្រការទី៥ : ហាមយកម្ហូបអាហារ រឺ របស់ខុសច្បាប់ ដូចជាគ្រឿងញៀន គ្រឿងផ្ទុះចូលក្នុងសាលា ។

ប្រការទី៦ : ហាមយកទូរស័ព្ទ ឬទទួលទូរស័ព្ទក្នុងថ្នាក់រៀនដែលបង្ករអោយមានសំលេងរំខានដល់ការសិក្សា ។

ប្រការទី៧ : សិស្សានុសិស្សត្រូវមានសំភារសិក្សាក្នុងពេលសិក្សាក្នុងថ្នាក់រៀន ។

ប្រការទី៨ : ចំពោះសិស្សានុសិស្សដែលអវត្តមានក្នុងការប្រលងទោះប្រចាំខែ ឬ ឆមាសក្តីត្រូវធ្វើការប្រលងសងនិងត្រូវផាកពិន័យតាមដែលសាលាកំណត់ ។ រាល់ការប្រលងធ្លាក់នូវមុខវិជ្ជាណាមួយត្រូវធ្វើការប្រលងសង រួមជាមួយនិងការផាកពិន័យផងដែរ ។

ប្រការទី៩ : រាល់ការឈប់ត្រូវសុំច្បាប់ដោយមានមូលហេតុសមរម្យស្របទៅនិងស្ថានភាពជាក់ស្តែង ។

### ចំពោះលោកគ្រូ-អ្នកគ្រូ

ប្រការទី១០ : លោកគ្រូ-អ្នកគ្រូជាអ្នកផ្តល់ចំណេះវិជ្ជាយ៉ាងសំខាន់ដល់សិស្សានុសិស្ស ដូចនេះសិស្សានុសិស្សទាំងអស់ត្រូវគោរពលោកគ្រូ-អ្នកគ្រូទាំងអស់នៅក្នុងសាលា ។

ប្រការទី១១ : ហាមចូលបន្ទប់លោកគ្រូ-អ្នកគ្រូដោយគ្មានការអនុញ្ញាត្ត ។

ប្រការទី១២ : ហាមចេញទៅក្រៅថ្នាក់ដោយគ្មានការអនុញ្ញាតពីលោកគ្រូ-អ្នកគ្រូ ។

### សំរាប់សំលៀកបំពាក់ឯកសណ្ឋាន

ប្រការទី១៣ : សិស្សានុសិស្សទាំងអស់ត្រូស្លៀកសំលៀកបំពាក់ដែលសាលាកំនត់ , ក្រវ៉ាត់ក និង ស្លាកឈ្មោះជានិច្ច ។

ប្រការទី១៤ : សិស្សានុសិស្សទាំងអស់ត្រូវកាត់សក់អោយបានសមរម្យ ។

ប្រការទី១៥ : បើសិស្សានុសិស្សល្មើស និង បទ បញ្ជាខាងលើ សាលានិងធ្វើការផាកពិន័យ ។ ក្នុងករណី មិនរៀងចាល សាលានិងធ្វើការបណ្តេញចេញពីសាលា ។

បទបញ្ជានេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ប៉ោយប៉ែត, ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១០ ។

**នាយកសាលា**